# សំណើ 41 ច្បាប់សញ្ញាប័ណ្ណកម្ចីឆ្នាំ 2014 នៃការការពារលំនៅដ្ឋានអតីតយុទ្ធជន និងជនគ្មានផ្ទះសម្បែងរបស់អតីតយុទ្ធជន។

## ★ ទឡ្ហីករណ៍គាំទ្រសំណើប្រជាមតិ 41 ★

បោះឆ្នោតគាំទ្រ លើសំណើប្រជាមតិ 41 ច្បាប់សញ្ញាប័ណ្ណកម្ចីឆ្នាំ 2014 នៃការការពារលំនៅដ្ឋានអតីតយុទ្ធជន និងជនគ្មានផ្ទះសម្បែងរបស់អតីតយុទ្ធជន ដើម្បីសង់លំនៅដ្ឋានមានតម្លៃថោកល្មមសំរាប់អ្នកជាអតីតយុទ្ធជននៅក្នុងរដ្ឋ California ដោយមិនចាំបាច់តំឡើង ពន្ធ ឬដាក់បញ្ចូលបំណុលរបស់រដ្ឋ California ដោយការបង្វិល ប្រាក់ $600 លានដុល្លារ នៃមូលនិធិដែលមានស្រាប់ មិនបានចំណាយ។

នេះជាការទទួលខុសត្រូវសារពើពន្ធនៃវិធានការសន្លឹកឆ្នោតដែលនឹងជួយអ្នកជាអតីតយុទ្ធជនជាអ្នកគ្មានផ្ទះសម្បែងរាប់ពាន់នាក់ទទួលបានដំបូលពីលើក្បាលរបស់គេ។ ច្បាប់នេះមិនមែនបង្កើតពន្ធថ្មី ឬដាក់បន្ថែមបំណុលថ្មីទៅរដ្ឋ California ទេ។ តាមពិត ច្បាប់នេះនឹងសំចៃប្រាក់ដុល្លាររបស់អ្នកបង់ពន្ធនៅក្នុងសុខាភិបាលនិងសុវត្ថិភាពសាធារណៈដោយយកអ្នកអតីតយុទ្ធជនចេញពីផ្លូវហើយដាក់នៅក្នុងលំនៅដ្ឋានមានសុវត្ថិភាព ថោកល្មម។

California គឺជាលំនៅដ្ឋានរបស់អតីតយុទ្ធជនគ្មានផ្ទះសម្បែងលើសពីមួយភាគបួននៅក្នុងសហរដ្ឋអាមេរិកទាំងមូល។ យើងត្រូវតែធ្វើច្បាប់ដើម្បីលើកឡើងនូវស្ថានការដ៏គក់ស្លុតនេះ តែយើងក៏ដឹងដែរថា California ធ្លាប់មានបញ្ហាថវិកាអស់រយៈកាលច្រើនឆ្នាំកន្លងមកហើយ។ ហេតុនេះហើយបានជាវិធានការនេះ *មិនបន្ថែមទៅក្នុងបំណុលរបស់ California ទេ;* ពុំនោះទេ វាត្រូវយកមូលនិធិសញ្ញាប័ណ្ណកម្ចីដែលបានអនុម័តពីមុនមក តែមិនបានចំណាយ ហើយប្រើវាដើម្បីសង់លំនៅដ្ឋានមានតម្លៃថោកល្មមសំរាប់អតីតយុទ្ធជនដែលគ្មានផ្ទះសម្បែង ជិតនឹងគ្មានផ្ទះសម្បែង សំរាប់រស់នៅ។ *យើងដឹងថា យើងត្រូវការធ្វើច្រើនទៀតដើម្បីអតីតយុទ្ធជនរបស់យើង ហើយយើងអាចធ្វើច្បាប់ដោយមិនចាំបាច់តំឡើងពន្ធថ្មីមួយសេន ឬបន្ថែមប្រាំសេនចូលទៅក្នុងបំណុលរបស់រដ្ឋ California។*

អតីតយុទ្ធជនម្នាក់ៗមានសេចក្តីត្រូវការពិសេសខុសៗគ្នា។ ហើយសកម្មភាពនេះនឹងជួយធានាដល់ការខិតចូលជិតអ្នកគ្មានផ្ទះសម្បែងក្នុងចំណោមអ្នកជាអតីតយុទ្ធជនបានទូលំទូលាយ។ ច្បាប់នេះនឹងជួយសង់លំនៅដ្ឋានអន្តរកាលសំរាប់អតីតយុទ្ធជនដែលសាកល្បងគេចចេញពីភាពគ្មានផ្ទះសម្បែងខណៈពេលដែលកំពុងសាងសង់លំនៅដ្ឋានឧបត្ថម្ភកិច្ចសំរាប់អតីតយុទ្ធជនដែលទាក់ទងជាមួយរបួសលើរាងកាយ, មានបញ្ហាសុខភាពផ្លូវចិត្ត, ឬការធ្លាក់ទឹកចិត្តក្រោយពេលមានគ្រោះថ្នាក់ (Post Traumatic Stress) ចាប់ផ្តើមពីការបំពេញសេវារបស់គេ។ អាទិភាពនឹងផ្តល់ជូនអង្គការមិនយកកម្រៃ និងរដ្ឋាភិបាលមូលដ្ឋានដើម្បីសង់លំនៅដ្ឋានថ្មី ឬកែលំអអគារដែលមានស្រាប់មកហើយដើម្បីតម្រូវតាមសេចក្តីត្រូវការរបស់អតីតយុទ្ធជនតាមមូលដ្ឋាន។

ដោយការបោះឆ្នោតគាំទ្រសំណើប្រជាមតិ 41 យើងអាចសម្រេចដើម្បីធានាថាអតីតយុទ្ធជនគ្មានផ្ទះសម្បែងមានសិទ្ធិទទួលលំនៅដ្ឋានមានគុណភាព ថោកល្មម ហើយផ្តល់ជូនអតីតយុទ្ធជនងាយរងគ្រោះនោះនូវឱកាសរកការហ្វឹកហ្វឺនការងារ, សេវាប្រឹក្សាទូន្មាន, និងសេវាស្តារនីតិសម្បទាដែលគេត្រូវការ—ហើយដោយច្បាប់នេះប្រើប្រាក់ដែលត្រូវបានអនុម័តរួចមកហើយ តែមិនទាន់បានចំណាយ យើងអាចផ្តល់កិត្តិយសដល់គេដោយមិនចាំបាច់បន្ថែមលើបំណុល ឬដំឡើងពន្ធឡើយ។

ដោយទំនាស់របស់យើងនៅបរទេសបានខិតដល់ការបញ្ចប់ អតីតយុទ្ធជនវ័យក្មេងប្រហែល 45,000 នាក់នឹងវិលត្រឡប់មកផ្ទះវិញនៅរដ្ឋ California។ ពួកគេបានធ្វើពលិកម្មច្រើនណាស់សំរាប់មាតុប្រទេសរបស់យើង ហើយអ្នកខ្លះអាចវិលត្រឡប់មកផ្ទះវិញដោយគ្មានការងារធ្វើ ឬគ្មានផ្ទះរង់ចាំគេ។ *យើងមិនអាចបណ្តោយឲ្យបុរស និងស្ត្រីទាំងនេះដែលបានបំរើមាតុប្រទេសឲ្យតែលតោលដោយគ្មានពំនឹងដល់ខ្លួនគេឡើយ។*

នេះហើយដែលអង្គការដូចជាកងអាវុធហត្ថអាមេរិកាំង(American Legion), អតីតយុទ្ធជនសង្គ្រាមវៀតណាមនៃរដ្ឋ California, ភូមិអតីតយុទ្ធជននៃ San Diego, អតីតយុទ្ធជន សហរដ្ឋអាមេរិក និងអង្គការ ពីដាវ ទៅផាល(Swords to Plowshares)គាំទ្រច្បាប់នេះ។ ពួកគេដឹងថាយើងត្រូវតែធ្វើត្រូវដោយអតីតយុទ្ធជន និងអ្នកបង់ពន្ធឲ្យដូចគ្នា។

បោះឆ្នោត គាំទ្រ សំណើប្រជាមតិ 41 ដើម្បីសង់លំនៅដ្ឋាន $600 លានដុល្លារដែលមានគុណភាព ថោកល្មមសំរាប់អតីតយុទ្ធជននៅ California ដោយមិនចាំបាច់ដំឡើងពន្ធ ឬបន្ថែមបំណុលទៅ California។ ផ្តល់កិត្តិយសដល់អតីតយុទ្ធជននៅ California ដែលបានធ្វើពលិកម្មសំរាប់យើង មិនត្រឹមតែជាករណីយកិច្ចរបស់យើងជាអ្នកបោះឆ្នោត—តែវាជាកាតព្វកិច្ចរបស់យើងជាពលរដ្ឋ។ ដើម្បីចង់ដឹងព័ត៌មានច្រើនថែមទៀត សូមទស្សនាគេហទំព័រ *www.yesonprop41forvets.org*។

ចូរយើងគាំទ្រអតីតយុទ្ធជនរបស់យើងចំពោះពលិកម្មរបស់គេ—ដោយការបោះឆ្នោតគាំទ្រ!

**JOHN A. PÉREZ,** អ្នកនាំពាក្យសភាតំណាងរាស្ត្ររដ្ឋ California
**LEON E. PANETTA,** អតីតលេខាធិការក្រសួងការពារជាតិសហរដ្ឋអាមេរិក
**STEPHEN PECK,** ប្រធាន
U.S. VETS

## ★ មតិប្រតិកម្មលើទឡ្ហីករណ៍គាំទ្រសំណើប្រជាមតិ 41 ★

ជាទូទៅ វាជាការទទួលខុសត្រូវរបស់រដ្ឋាភិបាលសហព័ន្ធក្នុងការមើលថែទាំអតីតយុទ្ធជនយោធា ក៏ប៉ុន្តែ កាលណារដ្ឋាភិបាលសហព័ន្ធថយចុះចំនួន ហើយគ្មាននរណាមួយទទួលយកការថមថយចុះនោះ វាជាការសមរម្យសំរាប់រដ្ឋាភិបាលថ្នាក់រដ្ឋជួយដល់ជនដែលបានបំរើការងារ—ទោះបីជាការស្ម័គ្រចិត្តក៏ដោយ—នៅក្នុងក្រុមយោធា។

ផ្តល់ការទទួលស្គាល់ដល់អង្គនីតិបញ្ញត្តិរដ្ឋ California សំរាប់សម្ដីនៅក្នុងសំណើប្រជាមតិ 41 ឲ្យផ្ទេរប្រាក់ $600 លានដុល្លារដែលអ្នកបោះឆ្នោតបានអនុម័តឲ្យខ្ចីសំរាប់កម្មវិធីនានាដែលជួយបំរើដល់សេចក្តីត្រូវការរបស់អតីតយុទ្ធជន។

ត្រូវចងចាំថា រាល់ប្រាក់ដែលបានខ្ចី (ដោយការលក់សញ្ញាប័ណ្ណកម្ចីនានា) ត្រូវតែបង់សងវិញជាមួយនិងការប្រាក់។

ក្នុងករណីនៃកម្មវិធី CalVet សំរាប់ការទិញផ្ទះ(និងចំការ) អ្នកទទួលសេវាត្រូវបានតម្រូវឲ្យបង់សងវិញកម្ចីជាមួយនឹងការប្រាក់។ ផ្ទុយទៅវិញ កម្មវិធីបានដាក់សម្ដីសំរាប់អតីតយុទ្ធជនគ្មានផ្ទះសម្បែងនឹងមិនត្រូវបានបង់សងវិញដោយអតីតយុទ្ធជន (ដោយពួកគេគ្មានសមត្ថភាពក្នុងការបង់សង)។

ម៉្យាងទៀត ត្រូវចងចាំកម្មវិធីណាមួយដែលពាក់ព័ន្ធនឹងការចំណាយមិនបានផ្តល់ដោយផ្ទាល់ទៅឲ្យអ្នកត្រូវទទួលជំនួយពិតគឺជាកម្មវត្ថុនៃកង្វះចំណាត់ចែង និងការខ្ជះខ្ជាយ។

នាពេលអនាគត មធ្យោបាយដ៏ល្អសំរាប់អ្នកគ្មានផ្ទះសម្បែងក្នុងចំណោមអតីតយុទ្ធជនគឺជៀសវាងនូវការប្តេជ្ញាអ្វីមួយដែលមិនចាំបាច់ត្រូវការពីកងពលលើដីសំរាប់សមរភូមិជុំវិញពិភពលោកទាំងមូល។ ការដាក់ *"ទាហានលើដី"* នៅលើដីបរទេសគឺនៅតែពេលណាជាករណីចុងក្រោយបំផុត។

**GARY WESLEY**



*ទឡ្ហីករណ៍ទាំងឡាយបានបោះពុម្ពនៅលើទំព័រនេះគឺជាគំនិតយោបល់របស់អ្នកនិពន្ធ ហើយពុំបានពិនិត្យមើលភាពត្រឹមត្រូវដោយមន្ត្រីទីភ្នាក់ងារណាមួយឡើយ។*

# សំណើ 41 ច្បាប់សញ្ញាប័ណ្ណកម្ចីឆ្នាំ 2014 នៃការការពារលំនៅដ្ឋានអតីតយុទ្ធជន និងជនគ្មានផ្ទះសម្បែងរបស់អតីតយុទ្ធជន។

## ★ ទឡ្ហីករណ៍ប្រឆាំងសំណើប្រជាមតិ 41 ★

ក្នុងឆ្នាំ 2008 អ្នកបោះឆ្នោតនៅ California បានអនុម័តិ $900 លានដុល្លារ វិធានការសញ្ញាប័ណ្ណកម្ចីដើម្បីជួយមូលនិធិដល់ចំការ CalVet និង កម្មវិធីកម្ចីទិញផ្ទះ ។ កម្មវិធីបានចាប់ផ្តើមក្នុងឆ្នាំ 1921។ កម្មវិធីនេះបានជួយអតីតយុទ្ធជនជាយោធានៅ California លើសពី 400,000 នាក់ទិញផ្ទះ (និងចំការ)។

នៅក្នុងសំណើប្រជាមតិនេះ អង្គសភារដ្ឋកំពុងធ្វើសម្មើឲ្យអនុញ្ញាតប្រើប្រាក់ $600 លានដុល្លារនៃប្រាក់ $900 លានដុល្លារនៃវិធានការសញ្ញាប័ណ្ណកម្ចីពីមុន (ពីរ-ភាគបី) សំរាប់កម្មវិធីណាមួយផ្សេងទៀតដែលមានគោលដៅជួយអតីតយុទ្ធជនគ្មានផ្ទះសម្បែង។ ដោយយោលតាមអង្គនីតិបញ្ញត្តិ មានអតីតយុទ្ធជនគ្មានផ្ទះសម្បែងប្រហែល 19,000 នៅក្នុង California—មានច្រើនមកថែមទៀត។

បើសិនជាត្រូវបានអនុម័តិដោយអ្នកបោះឆ្នោត សំណើប្រជាមតិនេះនឹងអនុញ្ញាតឲ្យមាន *"គណៈកម្មការហិរញ្ញវត្ថុផ្នែកលំនៅដ្ឋានសំរាប់អតីតយុទ្ធជន"* ដើម្បីខ្ចីប្រាក់ដោយការលក់ $600 លានដុល្លារ ក្នុងកាតព្វកិច្ចសញ្ញាប័ណ្ណកម្ចីទូទៅ *"ដើម្បីផ្តល់នូវការទទួលបាន,សំណង់, នីតិសម្បទាកម្ម, និងការរក្សាទុកលំនៅដ្ឋានឧបត្ថម្ភកិច្ចសំរាប់ពហុគ្រួសារមានតម្លៃថោក ឬអគារនានាដែលទាក់ទងសំរាប់អតីតយុទ្ធជន និងគ្រួសាររបស់គេក្នុងការទទួល និងរក្សាលំនៅដ្ឋានឲ្យមានស្ថេរភាព។"*

ដោយយោលតាមអង្គនីតិបញ្ញត្តិរដ្ឋ ប្រាក់ $900 លានដុល្លារដែលជាកម្ចី (ដោយការលក់សញ្ញាប័ណ្ណកម្ចី) ដែលបានអនុម័តិដោយអ្នកបោះឆ្នោតសំរាប់កម្មវិធីកម្ចី CalVet ក្នុង ឆ្នាំ 2008 គឺមិនត្រូវបានប្រើប្រាស់ពេញលេញដោយអតីតយុទ្ធជនសំរាប់ទិញផ្ទះ ឬចំការ។ តាមពិតអង្គនិតិបញ្ញត្តិរាយការណ៍អំណាចនៃការខ្ចីក្រោមច្បាប់មុន $500 លានដុល្លារ វិធានការសញ្ញាប័ណ្ណកម្ចីសំរាប់កម្មវិធីកម្ចីមិនទាន់ខ្សស់នៅឡើយទេ។

សំនួរចំបងៗដែលត្រូវបានលើកឡើងដោយសំណើប្រជាមតិនេះគឺ ៖

(1) គួរតែទឹកប្រាក់ $600 លានដុល្លារក្នុងសមត្ថភាពនៃកម្ចីអាចយកពីកម្មវិធីចំការ CalVet និងកម្មវិធីកម្ចីទិញផ្ទះបានដែរឬទេ?

(2) គួរតែទឹកប្រាក់ $600 លានដុល្លារអាចខ្ចី (ដោយការលក់សញ្ញាប័ណ្ណនានា) សំរាប់គាំទ្រកម្មវិធីអតីតយុទ្ធជន California ថ្មី?

**GARY WESLEY**

## ★ មតិប្រតិកម្មលើទឡ្ហីករណ៍ប្រឆាំងសំណើប្រជាមតិ 41 ★

សំណើ 41 ច្បាប់សញ្ញាប័ណ្ណកម្ចីឆ្នាំ 2014 នៃការការពារលំនៅដ្ឋានអតីតយុទ្ធជន និងជនគ្មានផ្ទះសម្បែងរបស់អតីតយុទ្ធជនបង្វែរសញ្ញាប័ណ្ណកម្ចីមានស្រាប់មកហើយ មិនបានចំណាយដែលត្រូវបានអនុម័តិពីមុនមកដោយអ្នកបោះឆ្នោតតែមិនដែលត្រូវបានប្រើ។ សំណើ 41 មិនដំឡើងពន្ធ ឬបន្ថែមពីលើបំណុលទាំងអស់របស់រដ្ឋ។ សំណើ 41 អនុញ្ញាតទឹកប្រាក់ចំនួន $600 លានដុល្លារសំរាប់ការសង់សំណង់ និងកែលំអលំនៅដ្ឋានមានតម្លៃថោកល្មមសំរាប់អតីតយុទ្ធជន និងអ្នកដែលជិត នឹងគ្មានផ្ទះសម្បែង។

កម្មវិធីមានស្រាប់មកហើយដែលមូលនិធិទាំងនេះបានមកគឺត្រូវបានប្រើប្រាស់ស្ទើរតែមិនគ្រប់គ្រាន់។ តាមពិតទៅ អ្នកនិពន្ធនាយកសារព័ត៌មាន *Los Angeles Times* មួយរូបបាននិយាយថាវិធានការសន្លឹកឆ្នោតលំនាំដើមដែលបានអនុញ្ញាតផ្តល់មូលនិធិនេះ "ខុសគំនូស ក្នុងការជួបតាមតំរូវការនៃអតីតយុទ្ធជនរបស់រដ្ឋ។" ដូច្នេះហើយបានជា សំណើ 41 មានសារសំខាន់ណាស់សំរាប់អតីតយុទ្ធជន—វាសង់ប្រភេទលំនៅដ្ឋានដែលបណ្តាអតីតយុទ្ធជននៅ California ត្រូវការដោយគ្មានដំឡើងពន្ធ។

ច្បាប់នេះបង្វែរសញ្ញាប័ណ្ណដែលបានអនុម័តិរួចមកហើយ តែមិនដែលបានប្រើ។ គឺមានន័យថាវាមិនបន្ថែមពីលើបំណុលទាំងឡាយបានអនុញ្ញាតរួចហើយរបស់ California។ ការប្រើសញ្ញាប័ណ្ណកម្ចីទាំងឡាយនេះនឹងបណ្តាលឲ្យមានថ្លៃហិរញ្ញវត្ថុតិចតួចដល់រដ្ឋខណៈដែលវានាំឲ្យមានការសំចៃក្នុងសេវានានា និងសុខាភិបាល។ ដូចសារព័ត៌មាន *L.A. Times* បានកត់សំគាល់ថា, "ដោយការកាត់បន្ថយចំនួនអតីតយុទ្ធជនគ្មានផ្ទះសម្បែង ហើយភ្ជាប់ពួកច្រើនថែមទៀតទៅនឹងសេវានីតិសម្បទាកម្ម និងសុខភាពផ្លូវចិត្តដែលពួកគេត្រូវការ សញ្ញាប័ណ្ណកម្ចីអាចជួយរដ្ឋ *ជៀសវាងថ្លៃចំណាយសំរាប់សេវាសុខាភិបាល និងសង្គមកិច្ច* ដែលគេប្រឈមមុខថ្ងៃនេះ" សារព័ត៌មាន *Times* ក៏កត់សំគាល់សញ្ញាប័ណ្ណទាំងនេះ *អាចជួយឲ្យអតីតយុទ្ធជនគ្មានផ្ទះសម្បែងឲ្យចូលរួមក្នុងកំឡាំងការងារវិញ។*

នេះជារបៀបទទួលខុសត្រូវសារពើពន្ធដែលធ្វើត្រូវដោយអតីតយុទ្ធជន California។ បោះឆ្នោតគាំទ្រ សំណើ 41 ដើម្បីជួយអតីតយុទ្ធជន California ទទួលបាននូវលំនៅដ្ឋានដែលគេត្រូវការ។

**ED FORD,** មេបញ្ជាការរដ្ឋ
អតីតយុទ្ធជននៃសង្គ្រាមបរទេស ផ្នែករដ្ឋ California
**PETER CAMERON,** នាយកប្រតិបត្តិ
Veterans Resource Center of America
**JOSEPH GARCIA,** មេបញ្ជាការរដ្ឋ
American Legion, ផ្នែករដ្ឋ California